នាងអេសធើរ១:១-៣

កណ្ឌព្រះគម្ពីរ

# នាងអេសធើរ

## សេចក្ដីផ្ដើម

យើងមិនដឹងច្បាស់ថា ជនណាម្នាក់ជាអ្នកកត់ត្រាទុកគម្ពីរនាងអេសធើរនេះទេ។ បើតាមសំនួនវោហារ យើងសន្និដ្ឋានថា ប្រហែលជាលោកម៉ាដេកាយ ដែលត្រូវជាឪពុកមារបស់នាងអេសធើរ។ យើងហ៊ានធ្វើការអះអាងយ៉ាងដូច្នេះ ពីព្រោះជំពូក ៤:១៤ សម្ដែងថា "ដ្បិតបើព្រះនាងនឹងស្ងៀមនៅក្នុងវេលានេះ នោះនឹងកើតមានសេចក្ដីសង្គ្រោះ នឹងសេចក្ដីប្រោសឱ្យរួច ដល់ពួកយូដាពីកន្លែងផ្សេងទៀត តែព្រះនាងនឹងញាតិវង្សរបស់បិតានៃព្រះនាងនឹងត្រូវវិនាសវិញ ហើយប្រហែលជាព្រះនាងបានតាំងឡើងក្នុងរាជ្យសំរាប់ពេលនេះឯងទេដឹង"។ រីឯជំពូក៩:២៩វិញ ក៏បានសម្ដែងបញ្ជាក់បន្ថែមដែរថា "គ្រានោះ អេសធើរដ៏ជាអគ្គមហេសី ជាបុត្រីអ័ប៊ីហែល ព្រមទាំងម៉ាដេកាយជាសាសន៍យូដាក៏សរសេរម្ដងទៀត ផ្ញើទៅដោយអាងគ្រប់អំណាចរបស់ខ្លួន ដើម្បីនឹងតាំងសំបុត្រពីបុណ្យពោរនោះ ទុកជាច្បាប់តទៅ "។

កណ្ឌព្រះគម្ពីរនាងអេសធើរ មានលក្ខណៈចម្លែកជាងគេនៅក្នុងព្រះគម្ពីរ

ទាំងមូល។ គម្ពីរនេះមានលក្ខណៈចម្លែក ទីមួយ ពីព្រោះក្នុងកណ្ឌព្រះគម្ពីរទាំង មូល មិនបានរៀបរាប់ពីព្រះនាមរបស់ព្រះជាម្ចាស់ទាល់តែសោះ។ មិនត្រឹមតែប៉ុណ្ណោះ សូម្បីសព្វនាមរបស់ព្រះជាម្ចាស់ ក៏មិនមានប្រើនៅក្នុងកណ្ឌព្រះគម្ពីរនេះដែរ។ ផ្ទុយទៅវិញ ស្តេចដែលជាសាសន៍ដទៃ មានរៀបរាប់ដល់ទៅចំនួន១៩២ដង។ ចំណែកសេចក្តីអធិស្ឋាន ក៏មិនឃើញមាននិយាយអ្វីដែរ។ រឿងនោះចាត់ទុកដូចជារឿងធម្មតា ដ្បិតមិនឃើញនិយាយពីព្រះជាម្ចាស់ ហើយក៏មិនឃើញនិយាយពីសេចក្តីអធិស្ឋាន។ រីឯព្រះគម្ពីរសញ្ញាថ្មីក៏មិនដែលយករឿងនាងអេសធើរមកយោងត្រង់ណាបន្តិចសោះ។ ប៉ុន្តែពាក្យទំនៀមរបស់សាសន៍ដទៃ បានយកមកនិយាយនៅក្នុងកណ្ឌព្រះគម្ពីរនេះទាំងមូល។ ពាក្យទំនៀមទាំងនោះមានឧទាហរណ៍ដូចជា ព្រេងសំណាង របៀបរស់នៅរបស់អ្នកមិនស្គាល់ព្រះជាម្ចាស់ ព្រមទាំងរោងជំនុំជំរះក្តីរបស់នគរមួយដែលនៅក្នុងសម័យដើម គេស្គាល់ថា ជានគរមហាអំណាចដែលមានឥទ្ធិពលខ្លាំងបំផុត។ ព្រះគម្ពីរនាងអេសធើរពិតជាកណ្ឌព្រះគម្ពីរដែលមានលក្ខណៈដោយឡែកមែន។

ម្យ៉ាងទៀត ព្រះគម្ពីរនាងអេសធើរមានលក្ខណៈដោយឡែក ត្រង់ដែលថាឈ្មោះព្រះគម្ពីរនេះ ហៅតាមឈ្មោះស្ត្រី។ នៅក្នុងព្រះគម្ពីរទាំងមូល មានកណ្ឌគម្ពីរដែលហៅតាមឈ្មោះស្ត្រីតែពីរកណ្ឌទេ គឺគម្ពីរនាងរស់ និងគម្ពីរនាងអេសធើរ។ អ្នកខ្លះចង់រាប់គម្ពីរយ៉ូហានថា ជាគម្ពីរឈ្មោះស្ត្រីដែរ។ តាមពិត រឿងនោះមិនមែនយ៉ាងដូច្នោះទេ។ ក្នុងគម្ពីរដែលមានឈ្មោះស្ត្រីទាំងពីរកណ្ឌ បើកសម្តែងអោយយើងឃើញនូវលក្ខណៈវិសេសស្រដៀងគ្នា។ គម្ពីរនាងអេសធើរផ្តល់នូវសេចក្តីពិត ដែលព្រះជាម្ចាស់

ស្រឡាញ់ដល់មនុស្សលោក។ ចំណែកសេចក្តីដែលសម្តែងនៅក្នុងគម្ពីរនាងអេសធើរវិញ សម្តែងពីការឧបត្ថម្ភមិនឈប់ឈរពីព្រះជាម្ចាស់។ សព្វថ្ងៃនេះ ព្រះជាម្ចាស់បញ្ជាអោយចក្រវាលយើងនេះ ធ្វើដំណើរតាមច្បាប់របស់ទ្រង់។ មនុស្សលោកតែងតែហៅច្បាប់របស់ព្រះជាម្ចាស់ថាជាច្បាប់ធម្មជាតិ។ ព្រះជាម្ចាស់កំពុងចាត់ចែងលោកសន្និវាសនេះអោយដើរតាមវិថីរបស់ខ្លួន។

នៅក្នុងព្រះគម្ពីរចោទិយកថា មានសេចក្តីចែងថា មុនព្រះជាម្ចាស់នាំសាសន៍អ៊ីស្រាអែល ចូរមកតាំងទីលំនៅនៅក្នុងទឹកដីសន្យា ទ្រង់មានបន្ទូលរួចជាស្រេចពីប្រវត្តិសាស្ត្ររបស់សាសន៍អ៊ីស្រាអែលក្នុងគ្រាអនាគត។ ព្រះអង្គមានបន្ទូលពីដំណើរសាសន៍អ៊ីស្រាអែល ដែលត្រូវក្លាយជាឈ្លើយសឹកចំនួនចិតសិបឆ្នាំក្នុងប្រទេស បាប៊ីឡូន។ មិនតែប៉ុណ្ណោះ ព្រះអង្គមានបន្ទូលពីដំណើរដែលសាសន៍រ៉ូម នឹងត្រូវមករំលាយទីក្រុងយេរូសាឡិម រួចហើយចាប់យកអ្នកស្រុកទៅធ្វើជាឈ្លើយសង្គ្រាម។ អ្វីៗដែលព្រះអម្ចាស់មានបន្ទូលមកនោះ បានកើតឡើងចេញជារូបរាងយ៉ាងច្រើនរួចទៅហើយ។ ប៉ុន្តែ នៅក្នុងព្រះគម្ពីរចោទិយកថា៣១:១៨ ព្រះជាម្ចាស់មានបន្ទូលថា "តែនៅថ្ងៃនោះអញនឹងគេចមុខចេញជាប្រាកដ ដោយព្រោះសេចក្តីអាក្រក់ទាំងប៉ុន្មាន ដែលគេបានប្រព្រឹត្តដោយងាកបែរទៅតាមព្រះដទៃ"។ តើការនោះសម្រេចឡើងនៅ ពេលណា?

ក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរ ព្រះជាម្ចាស់លាក់ព្រះភក្ត្ររបស់ទ្រង់ពីសាសន៍អ៊ីស្រាអែល។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះអង្គមិនលាក់ព្រះភក្ត្រទ្រង់

អោយជិត ព្រមទាំងបោះចោលវាស្ត្ររបស់ទ្រង់ជានិច្ចនិរន្តរ៍ទេ។ ព្រះអង្គគង់ពីខាងក្រោយស្ថានការណ៍ ដើម្បីឧបត្ថម្ភដល់រាស្ត្ររបស់ទ្រង់។ ដូច្នេះ ក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរ យើងឃើញមានឯកសារដែលកត់ទុកនូវស្ថានភាពរបស់មនុស្សមួយក្រុម ដែលដើរដាច់ចេញពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

កណ្ឌព្រះគម្ពីរនាងអេសធើរ មានលក្ខណៈដោយឡែកពីព្រះគម្ពីរដទៃទៀត ហេតុដូចម្តេចបានជាបែរទៅជាមានសារៈសំខាន់នៅក្នុងព្រះគម្ពីរទៅវិញ។ បន្ទាប់ពីធ្វើជាឈ្លើយសឹកចំនួនចិតសិបឆ្នាំនៅប្រទេសបាប៊ីឡូន ក្នុងខណៈដែលស្តេចស៊ីរុស ចេញបង្គាប់អោយសាសន៍អ៊ីស្រាអែលត្រឡប់មកនគររបស់ខ្លួនវិញ មានមនុស្សតិចណាស់ព្រមត្រឡប់មកធ្វើមាតុភូមិនិវត្តន៍។ បើតាមឯកសារដែលមានកត់ទុកនៅក្នុងព្រះគម្ពីរអែសរ៉ា នេហេមា ហាកាយ និងសាការី យើងឃើញថា មនុស្សប្រមាណតិចជាងប្រាំមួយម៉ឺននាក់ ព្រមត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញ។ ចុះពួកអ្នកដែលនៅសល់ទាំងអម្បាលមាណ គេនៅទីណាទៅ? ស្ថានភាពនោះ មិនខុសពីសាសន៍អ៊ីស្រាអែលសព្វថ្ងៃនេះទេ។ នៅក្នុងប្រទេសអ៊ីស្រាអែលទាំងមូល មានសាសន៍អ៊ីស្រាអែលសុទ្ធប្រមាណជាងពីរលាននាក់តែប៉ុណ្ណោះ។ ប៉ុន្តែបើយើងគិតស្ថិតិសាសន៍អ៊ីស្រាអែលនៅលើសកលលោកទាំងមូល មានប្រមាណជាដប់ប្រាំមួយលាន់នាក់ឯណោះ។ ដូច្នេះ បើប្រៀបធៀបសាសន៍អ៊ីស្រាអែលស្ថិតនៅក្នុងនគររបស់ខ្លួន ទៅនឹងសាសន៍អ៊ីស្រាអែលដែលរស់នៅពាសពេញសកលលោកទាំងមូល យើងឃើញថា មានចំនួនតិចណាស់ដែលព្រមត្រឡប់ទៅរស់នៅស្រុកកំណើតរបស់ខ្លួនវិញ។ បន្ទាប់ពីស្តេចស៊ីរុសចេញបញ្ជារួច

ហើយ មានសាសន៍អ៊ីស្រាអែលរាប់លាននាក់ ដែលមិនបានត្រឡប់ទៅស្រុករបស់ខ្លួន។ តាមពិតសាសន៍អ៊ីស្រាអែល ត្រូវតែត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ដ្បិតព្រះជាម្ចាស់បង្គាប់អោយគេធ្វើយ៉ាងដូច្នោះ។ ដោយសារគេមិនព្រមត្រឡប់ទៅស្រុកកំណើតរបស់គេវិញ ទើបគេរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ចុះអ្នកដែលរស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់រស់នៅឯណា? យើងអាចដឹងពីស្ថានភាពរបស់អ្នកទាំងនោះ ដ្បិតព្រះគម្ពីរនាងអេសធើរបានថែងនៅខាងមុខយើងនេះស្រាប់។ គ្រប់ទំព័រ កណ្ឌព្រះគម្ពីរនាងអេសធើរ បានសម្តែងពីសាសន៍យូដាដែលស្ថិតនៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ កណ្ឌព្រះគម្ពីរនាងអេសធើរ ជាព្រះគម្ពីរដ៏ស្តើងមួយក្បាល ដែលបានផ្តល់នូវប្រវត្តិសាស្ត្រយ៉ាងទូលំទូលាយរបស់សាសន៍អ៊ីស្រាអែល។ គម្ពីរនាងអេសធើរ មានសារៈសំខាន់ ដោយសារបានកត់ត្រាប្រវត្តិសាស្ត្ររបស់សាសន៍អ៊ីស្រាអែល ដែលរស់នៅក្រៅនគររបស់ខ្លួន។

នៅក្នុងកណ្ឌព្រះគម្ពីរនេះ យើងស្គាល់លក្ខណៈរបស់ព្រះជាម្ចាស់ពីហេតុការណ៍ផ្សេងមួយទៀត។ ទោះបីរាស្ត្ររបស់ទ្រង់រស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះអង្គយ៉ាងណាក៏ដោយ យើងឃើញថា ព្រះជាម្ចាស់នៅតែបន្តដឹកនាំ និងឧបត្ថម្ភដល់គេដដែល។ តើព្រះអង្គដឹកនាំរាស្ត្ររបស់ទ្រង់បែបណា? គឺដោយការទំនុកបំរុងនិងការឧបត្ថម្ភរបស់ទ្រង់។

តើពាក្យថា ព្រះជាម្ចាស់ឧបត្ថម្ភ មានន័យដូចម្តេច? នៅក្នុងព្រះគម្ពីរសញ្ញា

ចាស់ មានគោលទ្ធិធំៗ ដែលបានបង្ហាត់បង្រៀនដល់រាស្ត្រទ្រង់គ្រប់ជាតិ គ្រប់សាសន៍ គ្រប់កាលសម័យ។ គម្ពីរនិក្ខមនំ ព្រះជាម្ចាស់បង្ហាត់បង្រៀនយើងពីគោលទ្ធិនៃសេចក្តីប្រោសលោះ។ ព្រះគម្ពីរនាងរស់ ព្រះអង្គបង្រៀនអំពីសេចក្តីប្រោសលោះតាមរយៈសេចក្តីស្រឡាញ់។ កណ្ឌព្រះគម្ពីរយ៉ូប បង្ហាត់បង្រៀនពីការប្រែចិត្តពិតប្រាកដ។ កណ្ឌព្រះគម្ពីរនេះ បង្ហាត់បង្រៀនពីព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ។ ដូច្នេះនៅក្នុងព្រះគម្ពីរសញ្ញាចាស់មានគោលទ្ធិជំនឿជាច្រើន ដែលព្រះបានបង្ហាត់បង្រៀនដល់យើងជាអ្នកជឿដល់ទ្រង់។ ចំណែកនៅក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរវិញ បរិយាយពីការឧបត្ថម្ភរបស់ព្រះជាម្ចាស់។ សាសន៍អ៊ីស្រាអែលជាច្រើនលាននាក់រស់នៅក្រៅបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ គេមិនស្តាប់បង្គាប់ព្រះអង្គ ពីព្រោះព្រះអង្គបង្គាប់អោយគេត្រូវត្រឡប់មកនៅនគររបស់ខ្លួនវិញ។ គេមិនព្រមត្រឡប់មកវិញទេ ពីព្រោះគេលែងស្គាល់ព្រះជាម្ចាស់បាត់ទៅហើយ។ គេស្ថិតនៅឆ្ងាយពីព្រះជាម្ចាស់ ហើយគេមិនបានអំពាវនាវរកទ្រង់ពេលគេមានទុក្ខលំបាកដែរ។ គ្រាមនុស្សជំនាន់មុនមកដល់ទឹកដីនៃប្រទេសដទៃ គេនាំគ្នាយំ រួចហើយពោលថា "បើសិនជាខ្ញុំមិនរឭកដល់ឯង គឺបើខ្ញុំមិនចូលចិត្តនឹងក្រុងយេរូសាឡិម ជាជាងសេចក្តីអំណរយ៉ាងសំខាន់របស់ខ្ញុំ នោះសូមឱ្យអណ្តាតខ្ញុំជាប់នៅក្រអូមមាត់ចុះ (ទំនុកដំកើង១៣៧:៦)។ ឥឡូវគេភ្លេចពាក្យសម្តីដែលគេយំយែកកាលពីមុនបាត់ទៅហើយ។ គេមិនបើកមាត់និយាយពីស្រុកកំណើតទៀតទេ។ គេមិនសរសើរព្រះអង្គ គេមិនអធិស្ឋានរកព្រះនាមទ្រង់ឡើយ។ ដូច្នេះហើយ បានជាយើងឃើញថា កណ្ឌព្រះគម្ពីរនាងអេសធើរ ជាគម្ពីរមានលក្ខណៈ

ដោយឡែក។ ចុះចំណែកព្រះជាម្ចាស់វិញ តើព្រះអង្គបំភ្លេចរាស្ត្ររបស់ទ្រង់ដែរឬទេ? តើព្រះអង្គអាចដឹកនាំរាស្ត្ររបស់ព្រះអង្គបានដែរឬទេ បើគេរស់នៅក្រៅបំណងព្រះហឫទ័យរបស់ទ្រង់? មែនហើយ ព្រះជាម្ចាស់មិនបោះបង់ចោលរាស្ត្ររបស់ទ្រង់ទេ គឺទ្រង់នៅតែឧបត្ថម្ភដល់រាស្ត្រទ្រង់ជានិច្ច។ កណ្ឌព្រះគម្ពីរនាងអេសធើរបង្រៀនយើងពីហេតុការណ៍ដែលព្រះជាម្ចាស់ឧបត្ថម្ភរាស្ត្ររបស់ទ្រង់។ តើពាក្យថា ព្រះជាម្ចាស់ឧបត្ថម្ភ មានន័យដូចម្ដេច? ពាក្យថាព្រះជាម្ចាស់ឧបត្ថម្ភ គឺកិរិយាដែលព្រះហស្តរបស់ព្រះអង្គ ច្នៃស្ងួនព្រឹត្តិការណ៍ទាំងឡាយ ដែលកើតឡើងនៅក្នុងជីវិតមនុស្ស។ គម្ពីរទំនុកដំកើង១០៣:១៩សម្ដែងថា "ព្រះយេហូវ៉ាទ្រង់បានតាំងបល្ល័ង្កទ្រង់នៅលើស្ថានសួគ៌ ហើយរាជ្យទ្រង់ក៏គ្រប់គ្រងលើទាំងអស់"។ ឯគម្ពីរអេភេសូរ១:១១ ព្រះជាម្ចាស់សម្ដែងថា "ឱ្យរួមគ្នាមកក្នុងទ្រង់ ដែលយើងរាល់គ្នាបានកេរ្តិ៍អាករក្នុងទ្រង់ដែរ ដោយទ្រង់បានដំរូវយើងទុកជាមុន តាមដំរិះសំរេចរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ការទាំងអស់តាមដែលគាប់ព្រះហឫទ័យទ្រង់"។ ព្រះជាម្ចាស់កំពុងចាត់ចែងធ្វើអោយចក្រវាលនេះមានដំណើរការដូចយើងឃើញមានសព្វថ្ងៃនេះ។ អ្នកប្រាជ្ញខ្លះមានលោកអឹម៉រសិនជាដើម បានប្រកាន់ថា ពិភពលោកទាំងមូលប្រៀបដូចជាសេះ ឯមនុស្សជាអ្នកជិះលើកែបបញ្ឆាសេះអោយរត់ទៅមុខ។ មែនហើយ មនុស្សជាអ្នកជិះលើសេះមែន ប៉ុន្តែព្រះជាម្ចាស់ជាអ្នកកាច់ចង្កូតវាសនារបស់ជីវិតមនុស្ស។

ដើម្បីអោយយល់ខ្លឹមសារនៅក្នុងព្រះគម្ពីរនាងអេសធើរ យើងត្រូវយល់ពីពាក្យការឧបត្ថម្ភរបស់ព្រះជាម្ចាស់អោយបានច្បាស់លាស់សិន។ កាលណាយើងនិយាយ

ពីកិរិយាដែលព្រះជាម្ចាស់ឧបត្ថម្ភ យើងត្រូវយល់ពីទំនាក់ទំនងរវាងព្រះអង្គជាមួយនឹងលោកសន្និវាសដែលទ្រង់បង្កើតដោយព្រះហស្តរបស់ទ្រង់មក ពិសេស គឺមនុស្សលោកផ្ទាល់តែម្តង។

ពាក្យទីមួយដែលយើងត្រូវយល់ ទាក់ទងនឹងការឧបត្ថម្ភ គឺការបង្កបង្កើត។ ពាក្យថា បង្កបង្កើតមានន័យថា ព្រះជាម្ចាស់បានធ្វើអោយពិភពលោកទាំងមូលនេះកើតមានមកដោយសារព្រះបន្ទូលរបស់ទ្រង់។ លោកសន្និវាសយើងនេះ កើតមកដោយសារព្រះជាម្ចាស់មានបន្ទូលថា ចូរអោយពិភពលោកនេះកើតមានដូចយើងឃើញសព្វថ្ងៃនេះ។ អ្នកខ្លះមិនមែនជាអ្នកវិទ្យាសាស្ត្រផង ហ៊ានប្រកែកប្រណាំងថា មនុស្សលោកយើងនេះ កើតមកពីការវិវត្តន៍ពីធាតុមួយមកធាតុមួយ មកដល់សត្វស្វា ហើយរហូតមកដល់ជាមនុស្ស។ ការនោះគ្រាន់តែជាការសន្និដ្ឋានប៉ុណ្ណោះ។ គ្រាដែលលោកសន្និវាសនេះកកើតឡើងមក តើមនុស្សនៅឯណា? តើលោកសន្និវាសទាំងមូលនេះ ត្រូវទាក់ទងគ្នាដោយសារអ្វី? សូមកុំអោយយើងហ៊ានសន្និដ្ឋានថា ពិភពលោកយើងនេះមានជារៀងរហូតអោយសោះ។ បើហ៊ានប្រកាន់ថាយ៉ាងដូច្នេះមែន លោកអ្នកច្បាស់ជាធ្លាក់ទៅក្នុងប្រឡាយមួយដែលគិតថា ពិភពលោកនេះគ្មានដើមគ្មានចុង។ បើពិភពលោកច្បាស់ជាគ្មានដើមគ្មានចុងមែន ច្បាស់ជាមានអង្គណាមួយ ដែលគ្មានដើមគ្មានចុង បង្កើតអោយលោកសន្និវាសយើងសព្វថ្ងៃនេះ។ មានកត្តាពីរយ៉ាង ដែលយើងអាចស្ទង់មើលថា តើលោកសន្និវាសនេះកើតមកពីអ្វី? កត្តាទីមួយគឺការសន្និដ្ឋាន។ ការសន្និដ្ឋាន គឺជាទ្រឹស្តីដែលប្រកាន់ថា រាប់រយលានឆ្នាំកន្លងទៅ ពិភពលោកយើងនេះ មានការផ្ទុះមួយយ៉ាង

ធំ ហើយក៏បែកគ្នាទៅជាពិភពដាច់ដោយឡែកៗ ដូចយើងឃើញមានសព្វថ្ងៃនេះ។ ទ្រឹស្តីនេះ គឺជាការសន្និដ្ឋានតែប៉ុណ្ណោះ។ សូមកត់ចំណាំផងដែរថា ការសន្និដ្ឋាន ជាផ្នែកមួយនៃជំនឿ។

មួយទៀតយើងអាចទទួលស្គាល់ថា កំណើតពិភពលោកនេះ កើតឡើងដោយសារការបើកសម្តែងពីព្រះជាម្ចាស់។ ការបើកសម្តែងទាក់ទងនឹងជំនឿរបស់យើង។ បើយើងពិតជាគ្រីស្ទបរិស័ទ ដែលជឿដល់ព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះមែន យើងជឿថា ពិភពលោកយើងនេះ កើតមកដោយសារព្រះបន្ទូលរបស់ព្រះអង្គ។ រឿងនោះកើតឡើងដោយជំនឿ ពីព្រោះយើងជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គម្ពីររ៉ូម១០:១៧ សម្តែងថា "ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ"។ មនុស្សយើងអាចទទួលយកហេតុការណ៍ពីរយ៉ាងទាក់ទងនឹងការកកើតផែនដី ទីមួយ គឺទទួលដោយការសន្និដ្ឋាន ទីពីរ ទទួលដោយសេចក្តីជំនឿ។ នៅចន្លោះហេតុការណ៍ទាំងពីរនេះគ្មានការសម្អាងអ្វីទៀតទេ។ ទាក់ទងនឹងរឿងការកកើតលោកសន្និវាសនេះ មិនមានការពន្យល់ណាទៀតឡើយ។ ការសន្និដ្ឋានក៏ជាជំនឿឯការពឹងពាក់លើព្រះបន្ទូលក៏ជាជំនឿ។ ការសន្និដ្ឋានជាជំនឿលើទ្រឹស្តីរបស់មនុស្ស។ រីឯការបើកសម្តែង គឺជំនឿលើព្រះបន្ទូលរបស់ព្រះ។

ពាក្យទីពីរដែលយើងត្រូវយល់ ដើម្បីអោយជ្រាបច្បាស់ពីការឧបត្ថម្ភរបស់ព្រះជាម្ចាស់ គឺការថែទាំ។ ពាក្យថា ថែទាំ គឺជាកិរិយាដែលព្រះជាម្ចាស់រក្សាលោកសន្និវាសយើងនេះ ធ្វើចលនាយ៉ាងទៀងទាត់។ គម្ពីរហេព្រើរ១:៣សម្តែងពីអង្គព្រះយេស៊ូវគ្រីស្ទ

ថា "គឺទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់ ទាំងទ្រទ្រង់គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូលដ៏មានព្រះចេស្ដានៃទ្រង់ ហើយក្រោយដែលបានសំអាតអំពើបាប របស់យើងរាល់គ្នាទាំងប៉ុន្មាន នោះក៏គង់នៅខាងស្ដាំនៃឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់"។ គម្ពីរកូល៉ុស១:១៧ សម្ដែងដែរថា "ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏នៅស្ថិតស្ថេរដោយសារទ្រង់"។ តើលោកសន្និវាសយើងសព្វថ្ងៃទាក់ទងគ្នាដោយសារជំរអ្វី? យើងឃើញថា ចក្រវាលសព្វថ្ងៃ ដើរទៀងដូចនាឡិកាដែលពាក់នៅលើកដៃរបស់យើងដែរ។ បើចក្រវាលនេះដើរមិនទៀង ដូចនាឡិកាយើងទេ អ្នកវិទ្យាសាស្ត្រមិនអាចធ្វើអ្វីបានឡើយ។ ពេលអ្នកវិទ្យាសាស្ត្រចង់ធ្វើដំណើរទៅឋានព្រះចន្ទ គេដឹងច្បាស់ថា ត្រូវបង្ហោះយានបែបណា ដាក់ប្រេងចំនួនប៉ុន្មាន កម្លាំងប៉ុន្មាន ហោះរយៈពេលប៉ុន្មានទើបទៅដល់។ បើព្រះជាម្ចាស់មិនរក្សាឋានព្រះចន្ទ និងផែនដីនេះនៅជិតគ្នាជាចលនានឹងនទេ អ្នកវិទ្យាសាស្ត្រច្បាស់ជាបើកយានអវកាសហួសទីនោះជាមិនខាន។ ម្យ៉ាងវិញទៀត សព្វថ្ងៃគេកំពុងរិះរកមធ្យោបាយ ដើម្បីហោះទៅកាន់ផ្កាយព្រះអង្គារទៀត។ បើផ្កាយព្រះអង្គារនៅម្ដងឆ្ងាយ ម្ដងជិតពីផែនដី មនុស្សលោកមិនអាចធ្វើដំណើរទៅដល់ទីនោះបានទេ។ តើនរណាជាអ្នកធ្វើអោយចលនារបស់លោកសន្និវាសនេះ ប្រព្រឹត្តទៅយ៉ាងទៀងទាត់ដូច្នេះ? ព្រះអម្ចាស់យេស៊ូវ កំពុងថែរក្សាលោកសន្និវាសយើងនេះ។ ទ្រង់ថែរក្សាអ្វីៗទាំងអស់ ព្រមទាំងធ្វើមនុស្សលោកអោយមានដំណើរការទៀងទាត់ដូចសព្វថ្ងៃនេះ ដោយសារព្រះបន្ទូលរបស់ទ្រង់ដ៏មានគ្រប់ទាំងព្រះចេស្ដា។

ពាក្យទីបី គឺការឧបត្ថម្ភនេះតែម្តង។ ការឧបត្ថម្ភរបស់ព្រះជាម្ចាស់ជាគន្លឹះសម្រាប់យល់ព្រះគម្ពីរនាងអេសធើរ។ ព្រះជាម្ចាស់ឧបត្ថម្ភដោយធ្វើអោយពិភពលោកយើងនេះ មានដំណើរការទៀងទាត់ដូចយើងឃើញស្រាប់។ ឧទាហរណ៍ពីដំណើរព្រះជាម្ចាស់ផ្គត់ផ្គង់ មានសម្តែងក្នុងកិរិយាដែលលោកអ័ប្រាហាំនិយាយទៅកាន់កូនរបស់លោក ពេលដែលលោកនាំទៅធ្វើជាយញ្ញបូជានៅភ្នំម៉ូរីយ៉ា។ នៅពេលជិតទៅដល់កន្លែង អ៊ីសាកសួរដល់ឪពុកថា "...លោកឪពុកអើយ គាត់ក៏ឆ្លើយថា អីកូនរួចវានិយាយថា នេះមានភ្លើងនឹងឧសហើយ តែកូនចៀមសំរាប់ដង្វាយដុតតើនៅឯណា អ័ប្រាហាំឆ្លើយថា កូនអើយ កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឱ្យ ដូច្នេះក៏នាំគ្នាទៅទៀត (លោកុប្បត្តិ២២:៧-៨)។ ដំណើររឿងនោះកើតឡើងដូចគ្នា ពីរពាន់ឆ្នាំក្រោយមកទៀត។ ព្រះជាម្ចាស់ប្រទានអោយចៀមរបស់ទ្រង់ គឺព្រះអម្ចាស់យេស៊ូវ មកសុគតនៅលើភ្នំដដែលនេះ គឺភ្នំកាល់គូថា។ នៅលើភ្នំនេះគេយកព្រះយេស៊ូវទៅឆ្កាងជំនួសមនុស្សមានបាប។ ព្រះអង្គជាកូនចៀមនៃព្រះ ដ្បិតគម្ពីរយ៉ូហាន១:២៩សម្តែងថា "...យ៉ូហានឃើញព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងមកឯគាត់ នោះក៏ពោលថា នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក"។ ការទាំងនេះហើយដែលហៅថា ព្រះជាម្ចាស់ឧបត្ថម្ភដល់មនុស្សលោក។

ពាក្យថា ព្រះជាម្ចាស់ឧបត្ថម្ភ មានន័យថា ព្រះហស្តព្រះជាម្ចាស់កំពុងថ្នៃសូនព្រឹត្តការណ៍ទាំងឡាយនៅក្នុងជីវិតរបស់មនុស្ស។ ព្រះជាម្ចាស់អោយមនុស្សជាអ្នកកាច់ចង្កូត ប៉ុន្តែ ព្រះអង្គជាអ្នកកាន់ចង្កូត។ ទ្រង់ជាអ្នកបង្គាប់ដល់អ្នកបើកនាវាទាំងឡាយ។

ព្រះអង្គជាអ្នកបង្កើតអោយមានយាមពេលយប់ ដើម្បីអោយអ្នកបើកនាវាសមុទ្រអាចស្គាល់ច្បាស់ថា វេលាម៉ោងប៉ុន្មាន គេធ្វើដំណើរដល់ណាហើយ។ ទ្រង់ជាត្រចៀកទ្វារដែលផ្ទុកទម្ងន់ទ្វារយ៉ាងធំ។ ទ្រង់ជាអង្គដែលធ្វើអោយសម្លេងក្មេងយំម្នាក់ចាក់ចុចដល់ចិត្តរបស់រាជបុត្រីរបស់ស្តេចផារ៉ោននៅមាត់ទន្លេនីល។ ទ្រង់ជាព្រះដែលក្តិចអោយលោកម៉ូសេយំ ហើយសម្លេងយំរបស់លោកម៉ូសេឮដល់ត្រចៀករបស់ព្រះនាង ដែលជាព្រះរាជបុត្រីរបស់ស្តេចផារ៉ោន។ ព្រះអង្គប្រើសម្លេងតូចឆ្មារ ដើម្បីប្តូរវាសនារបស់មនុស្សក្នុងពិភពលោកទាំងមូល។ ការនោះហៅថា ជាសេចក្តីឧបត្ថម្ភរបស់ព្រះជាម្ចាស់។ ការឧបត្ថម្ភរបស់ព្រះជាម្ចាស់ គឺកើតឡើងដោយសារព្រះហស្តរបស់ព្រះអង្គដ៏មានព្រះជន្មរស់។

កណ្ឌព្រះគម្ពីរនាងអេសធើរ បើកបង្ហាញអោយយើងស្គាល់នូវហេតុការណ៍ដែលព្រះជាម្ចាស់ឧបត្ថម្ភដល់មនុស្សលោក។ នាមរបស់ទ្រង់មិនមាននិយាយនៅក្នុងគម្ពីរក៏ពិតមែន ប៉ុន្តែកិរិយារបស់របស់ទ្រង់ ស្តីអំពីការឧបត្ថម្ភ មានរៀបរាប់នៅក្នុងទំព័រកណ្ឌព្រះគម្ពីរនាងអេសធើរដ៏ស្តើងនេះ។ ឥឡូវសូមយើងសិក្សាកណ្ឌព្រះគម្ពីរនាងអេសធើរដោយពិស្តារដូចតទៅ។

# ជំពូក ១

*ខាងចនា ភរិយាដែលបង្គាប់កិត្តិយសប្តី*

នៅក្នុងជំពូក១នេះ យើងឃើញប្រវត្តិសាស្ត្ររបស់ត្រកូលដែលមិនស្គាល់ព្រះជាម្ចាស់ត្រូវយកមកបញ្ចូលនៅក្នុងព្រះគម្ពីររបស់ទ្រង់។ ព្រះជាម្ចាស់ពិតជាមានបំណងព្រះហឫទ័យមួយដោយឡែក ចំពោះយើងទាំងអស់គ្នា ដែលជារាស្ត្ររបស់ទ្រង់។ ទ្រង់ចង់អោយយើងស្គាល់ពីការឧបត្ថម្ភរបស់ទ្រង់។ យើងនឹងឃើញហេតុការណ៍នេះនៅក្នុងពេលដែលយើងសិក្សាកណ្ឌព្រះគម្ពីរនាងអេសធើរ។ កណ្ឌព្រះគម្ពីរនេះ ចាប់ផ្តើមដោយពណ៌នាពីប្រពៃណីរបស់នគរមួយ ដែលមានច្បាប់យ៉ាងចម្លែក។ រីឯទំនាក់ទំនងរវាងប្តីហើយនិងប្រពន្ធ ក៏មានលក្ខណៈពិបាកយល់ខ្លាំងណាស់ដែរ។ ទំនាក់ទំនងរវាងមហាក្សត្រហើយនឹងអគ្គមហេសី ជារឿងផ្ទៃក្នុងរបស់នគរ តែរឿងនេះទាក់ទងនិងស្ថានភាពច្របូកច្របល់នៅក្នុងសកលលោកទាំងមូល។

**រីឯនៅគ្រាអ័ហាស៊ូរុស ជាស្តេចដែលសោយរាជ្យលើ១២៧ខេត្ត ចាប់តាំងពីស្រុកហិណ្ឌូ រហូតដល់អេធីយ៉ូពី (នាងអេសធើរ១:១)។**

យើងត្រូវយល់ថា អ័ហាស៊ូរុស មិនមែនជាឈ្មោះរបស់បុគ្គលណាមួយទេ

ពេលគឺគ្រាន់តែជាងាររបស់បុគ្គលម្នាក់។ ពាក្យនេះមានន័យថា ជាព្រះបិតា ឬក៏ជាព្រះមហាក្សត្រាធិរាជ។ នៅក្នុងសាសន៍រ៉ូម គេថ្វាយងារស្តេចថា សេសារ គឺមិនមែននាមរបស់ស្តេចនោះនាមសេសារទេ គឺគ្រាន់តែជាងាររបស់ស្តេចនោះប៉ុណ្ណោះ។ ដូច្នេះ អ័ហាស៊្វេរុស គឺជាងារស្តេចពើស៊ីដែលសម្តែងនៅក្នុងប្រវត្តិសាស្ត្រខាងលោកីយ៍។ សូមជ្រាបថា ហេតុការណ៍នេះមានការយល់ដឹងខុសៗគ្នា ស្តីពីដំណើរស្តេចអ័ហាស៊្វេរុស។

ចំពោះការយល់ដឹងរបស់ខ្ញុំវិញ ខ្ញុំយល់ថា ស្តេចអ័ហាស៊្វេរុស ដែលសម្តែងនៅក្នុងគម្ពីរនាងអេសធើរ គឺជាមហាក្សត្រាធិរាជនាមស៊្វេរុស។ ស្តេចអង្គនេះ ជាអ្នកនាំអោយចក្រភពពើស៊ីមានការរីកចម្រើន និងមានមហិទ្ធិឫទ្ធិដ៏កំពូល។ ស្តេចស៊្វេរុសធ្វើអោយលោកខាងកើតមានប្រៀបលើលោកខាងលិច។ ដើម្បីធ្វើសង្គ្រាមបែបនោះ ស្តេចអង្គនេះត្រូវមានការប្រឹងប្រែងយ៉ាងខ្លាំង។ ឯកសារដែលតម្កល់ទុកនៅសារៈមន្ទីរនៃប្រទេសអង់គ្លេសសព្វថ្ងៃ សម្តែងថា ស្តេចអ័ហាស៊្វេរុស និងព្រះនាងអេសធើរ គឺជាព្រះមហាក្សត្រា និងព្រះមហាក្សត្រយានី ជាបិតា និងមាតារបស់ស្តេចស៊្វេរុស បើតាមគម្ពីរអេសាយ៤៤:២៨ និង៤៥:១។

ស្តេចស៊្វេរុសសោយរាជ្យក្នុងចក្រភពទាំងមូល ដែលមានព្រំដែនលាតសន្ធឹងពីប្រទេសឥណ្ឌាទៅដល់ប្រទេសអេធីយ៉ូពី។ ដែនដីនេះ ជាដែនដីសណ្តដែលយើងរាប់ថាជាបេះដូងនៃសកលលោកទាំងមូល។

**២ ក្នុងគ្រានោះ កាលស្តេចអ័ហាស៊្វេរុសទ្រង់គង់លើបល្ល័ង្ករាជ្យនៅ**

**ស៊ូសាន ជាទីក្រុងហ្លួង ៣គឺនៅឆ្នាំទី៣ ក្នុងរាជ្យទ្រង់ នោះទ្រង់**
**បានជប់លៀងដល់ពួកអ្នកជាប្រធាន នឹងពួកជំនិតទ្រង់ មានទាំង**
**ពួកមេទ័ពសាសន៍ពើស៊ី នឹងសាសន៍មេឌី ពួកអ្នកធំ នឹងពួកចៅ**
**ហ្វាយខេត្តទាំងប៉ុន្មាននៅចំពោះទ្រង់ដែរ (នាងអេសធើរ១:២-**
**៣)។**

ពិធីជប់លៀងមួយនេះ ជាពិធីជប់លៀងយ៉ាងអធិកអធមជាទីបំផុត។ នៅក្នុងអំឡុងធ្វើពិធីជប់លៀងធំនោះ សេចក្ដីអម៉ាស់របស់ស្ដេចគ្រងរាជ្យ បានកើតមានឡើង។ ចក្រភពពើស៊ីទាំងមូល មានបណ្ដាខេត្តទាំងអស់ចំនួន១២៧។ ខេត្តនីមួយៗ គឺជានគរតែម្ដង។ ស្ដេចស៊ូរុសបានរៀប ចំពិធីជប់លៀងយ៉ាងអធិកអធម ដោយកោះហៅប្រតិភូពីចំនួន១២៧ខេត្តអោយចូលរួម។ យើងមិនដឹងថា ក្នុងប្រតិភូមួយក្រុមៗមានមនុស្សចំនួនប៉ុន្មាននាក់ទេ។ បើតាមភាពអធិកអធម និងសេចក្ដីអៀនខ្មាស ជាលក្ខណៈសកលរបស់ក្សត្រស៊ូរុស យើងសន្និដ្ឋានថា ប្រតិភូដែលមកពីខេត្តទាំង១២៧ មានយ៉ាងតិចបំផុតពីមួយពាន់ទៅពីរពាន់នាក់ឯណោះ។ ពិធីជប់លៀងនេះ មានលក្ខណវិសេស និងអធិកអធមយ៉ាងខ្លាំង។ បើតាមយើងប្រមាណមើលពិធីជប់លៀងនេះ ចំណាយអស់ថវិការាប់លានដុល្លាសហរដ្ឋអាមេរិក។ ពិធីជប់លៀងមួយនេះជាពិធីជប់លៀងចុងក្រោយបង្អស់ ដែលមិនដែលមានពិធីជប់លៀងបែបនេះទៀតទេ។ នៅក្នុងប្រវត្តិសាស្ត្រសកលលោក ព្រឹត្តិការណ៍មួយនេះ ជាព្រឹត្តិការណ៍ធំជាងគេបំផុត។ តើហេតុដូចម្ដេចបាន

ជាព្រះជាម្ចាស់យកព្រះទ័យទុកដាក់ជាមួយនឹងព្រឹត្តិការណ៍ ដែលស្ដេចស៊ូរុសរៀបចំពិធីជប់លៀងយ៉ាងធំនេះ? លោកអ្នកបងប្អូនអើយ ការនេះហើយ គឺជាសេចក្ដីឧបត្ថម្ភរបស់ព្រះជាម្ចាស់។ ព្រះអង្គបង្កើតអោយមានការនោះកើតឡើង ដើម្បីព្រះអង្គអាចសម្ដែងអោយរាស្ត្ររបស់ទ្រង់ឃើញថា ទ្រង់នៅតែយកព្រះហឫទ័យទុកដាក់ជាមួយនឹងប្រវត្តិសាស្ត្ររបស់មនុស្សលោក។ ព្រះជាម្ចាស់ឈរពីក្រោយស្ថានភាពផ្សេងៗ ដើម្បីឃ្លាំមើលរាស្ត្ររបស់ទ្រង់ដែលកំពុងធ្វើដំណើរឆ្លងកាត់សាគរជីវិត នៅក្នុងលោកសន្និវាស ដែលព្រះជាម្ចាស់បង្កើតមក។

យើងស្លេះការសិក្សាគម្ពីរនាងអេសធើរត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះជាមួយនឹងព្រះយេស៊ូវជាមិនខាន!"